ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៩ សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០០២

# សេចក្តីជូនដំណឹង

ស្តីពី

## ការអនុវត្តន៏ប្រមូលពន្ធលើ មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបលោក-លោកស្រីដែលជាម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា : ចាប់តាំងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ចេញប្រកាស លេខ ៣៤៩ សហវ.ពដ ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០២ និងសេចក្តីជូនដំណឹងលេខ ០១៧ សហវ.ពដ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០២ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០២ លោក-លោកស្រីជាម្ចាស់យានយន្តគ្រប់ប្រភេទមួយចំនួន ប្រកបដោយស្មារតីភ្ញាក់រលឹកយកចិត្តទុកដាក់គោរពកាតព្វកិច្ចបង់ពន្ធ យ៉ាងច្រើនកុះករជាបន្តបន្ទាប់ ។

ជាថ្មីម្តងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជំរាបជូនលោក-លោកស្រី ជាម្ចាស់យានយន្តគ្រប់ប្រភេទជ្រាបថា : ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០២ គឺត្រូវចាប់អនុវត្តពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០២ ដោយម្ចាស់យានយន្តនីមួយៗ ត្រូវបំពេញលិខិតប្រកាសចំនួន ០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ។ លិខិតប្រកាសនេះមានតំលៃ **មួយសន្លឹក ២០០រៀល** ។ ចំណូលពីការលក់លិខិតប្រកាស ត្រូវបង់ចូលថវិការដ្ឋ ។

ចាប់ពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០២តទៅ នឹងត្រូវអនុវត្តការផាកពិន័យតាមច្បាប់ជាធរមាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសង្ឃឹម និង ជឿជាក់លើស្មារតីយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់សាខាពន្ធដារគ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ